# កំណត់ហេតុ

# កិច្ចប្រជុំស្តីពី

# ការឆ្លុះបញ្ចាំងអំពីការប្រតិបត្តិល្អរបស់អង្គការសហគមន៍មូលដ្ឋាន និងការយល់ដឹងអំពីក្របខណ្ឌច្បាប់








www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152
F +855 (0)23 216 009

#9-11, Street 476,
ToulTompoung 1, Chamkamorn
P.O. Box 885, Phnom Penh,Cambodia

# ការសង្ខេបនៃកិច្ចប្រជុំ

| | |
|---|---|
| **សម្របសម្រួលដោយ៖** | កញ្ញា កៅ ពៅលក្ខិណា<br>អ្នកឯកទេសផ្នែកអង្គការសហគមន៍មូលដ្ឋាន |
| **អ្នកកត់ត្រាចំនុចសំខាន់ៗ៖** | ស្រេង សោភ័ណលក្ខិណា |
| **ចំនួនអ្នកចូលរួម៖** | • **ចំនួនសរុបអ្នកចូលរួម៖ ៤៨ នាក់**<br>• ចំនួនសហគមន៍ ៖ ៣០នាក់<br>• ចំនួនអង្គការដែលដឹកនាំសហគមន៍៖ ១២នាក់<br>• ចំនួនអង្គការ គ.ស.ក ៖០៧នាក់<br>• ចំនួនស្ត្រីមាន៖ ២០នាក់ |
| **ថ្ងៃខែឆ្នាំ និង ពេលវេលា** | ថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ២០១៨ ចាប់ពីម៉ោង ០១៖០០ រសៀល – ០៥៖០០ល្ងាច |
| **ទីកន្លែង** | ដាយកូនៀសិនធើ ផ្ទះលេខ១៩-២១ផ្លូវលេខ៣៣០ សង្កាត់បឹងកេងកង៣ ខណ្ឌចំការមន រាជធានីភ្នំពេញ |

## គោលដៅចំបងៗនៃវេទិកាគឺ៖

១. ដើម្បីធ្វើការឆ្លុះបញ្ចាំង ថាតើអង្គការសហគមន៍មូលដ្ឋានធ្វើការប្រតិបត្តិតាមគោលការណ៍ណែនាំស្តីពីការប្រតិបត្តិល្អរបស់អង្គការសហគមន៍មូលដ្ឋាន និងអភិវឌ្ឍសហគមន៍របស់គាត់បានដល់កម្រិតណា

២. ដើម្បីស្វែងយល់ពីបញ្ហាប្រឈមរបស់អង្គការសហគមន៍មូលដ្ឋាន និងតម្រូវការគាំទ្រពីអង្គការ គ.ស.ក និងអង្គការសង្គមស៊ីវិលដទៃទៀត

៣. ដើម្បីឲ្យអង្គការសហគមន៍មូលដ្ឋានត្រៀមខ្លួនសម្រាប់កិច្ចពិគ្រោះយោបល់ថ្នាក់ជាតិស្តីពី «ការអភិវឌ្ឍគោលនយោបាយ និងក្របខណ្ឌច្បាប់ពាក់ព័ន្ធនឹងអង្គការសង្គមស៊ីវិល»

## លទ្ធផលនៃវេទិកាសិក្សា

ការណែនាំអំពីគោលបំណងនៃកិច្ចប្រជុំរបស់អង្គការសហគមន៍មូលដ្ឋាន ដោយកញ្ញា កៅ ពៅលក្ខិណា អ្នកឯកទេសផ្នែកអង្គការសហគមន៍មូលដ្ឋាន

កញ្ញាបានណែនាំពីគោលបំណង និងរបៀបវារៈនៃកិច្ចប្រជុំរបស់អង្គការសហគមន៍មូលដ្ឋាន នឹងអញ្ជើញ **លោក សឿង សារឿន** នាយកប្រតិបត្តិ អង្គការ គ.ស.ក ថ្លែងសន្ទរកថាស្វាគមន៍។


www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152
F +855 (0)23 216 009

#9-11, Street 476,
ToulTompoung 1, Chamkamorn
P.O. Box 885, Phnom Penh,Cambodia
Accountability គណនេយ្យភាព GPP Symbol of Trust 25/08/2015 24/08/2018

## សន្ទរកថាស្វាគមន៍ និងបើកកម្មវិធី ដោយលោក សឿង សារឿន នាយកប្រតិបត្តិអង្គការគ.ស.ក



លោកបានស្វាគមន៍យ៉ាងកក់ក្តៅដល់សិក្ខាកាម ដែលបានចូលរួម លោកក៏បានគូសបញ្ជាក់ដែលថា បរិបទសង្គម នយោបាយ និងសេដ្ឋកិច្ចមានការផ្លាស់ប្តូរច្រើន ហើយលោកសូមកោតសរសើរចំពោះភាពជាអ្នកដឹកនាំរបស់គណ:កម្មការដែលបានបង្កើតអង្គការសហគមន៍មូលដ្ឋានឡើង នេះជាការផ្តួចផ្តើមមួយដ៏សំខាន់ ហើយសុទ្ធតែជាអ្នកដែលមានឆន្ទ:ខ្ពស់ និងមានទស្សន:វែងឆ្ងាយ ដើម្បីបន្សល់ទុកជាកេរមរតកដល់កូនចៅជំនាន់ក្រោយ។ លោកក៏បានបន្ថែមទៀតថាអង្គការ គ.ស.ក សូមធ្វើជាចំណែក ក្នុងការចូលរួមពង្រឹងកសាងសមត្ថភាពជាមួយអង្គការសហគមន៍មូលដ្ឋានរបស់លោកអ្នកផង ។ ម៉្យាងទៀត អង្គការសហគមន៍មូលដ្ឋានជាកត្តាសំខាន់ក្នុងការគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពនៅកម្ពុជា ដោយមើលឃើញថាសហគមន៍របស់លោកអ្នកកំពុងតែត្រូវការការពង្រឹងសមត្ថភាពយ៉ាងរឹងមាំ ហើយក៏ឃើញថាអង្គការសហគមន៍មូលដ្ឋានត្រូវការធនធានសមស្របផ្តោតសំខាន់នោះគឺថវិកា ដើម្បីបង្កើនសកម្មភាពការងារប្រកបដោយប្រសិទ្ធភាព ហើយរយ:ពេល ១ឆ្នាំឬ ៥ឆ្នាំទៅមុនទៀតនេះ អង្គការ គ.ស.ក នឹងប្តេជ្ញាចិត្តជួយពង្រឹងអង្គការសហគមន៍មូលដ្ឋាន បណ្តាញសង្គមស៊ីវិលតាមខេត្ត។ លោកបានបន្តថា ប៉ុន្មានថ្ងៃមុន អង្គការ គ.ស.ក បានចុះអនុសារណ:ជាមួយបណ្តាញសង្គមស៊ីវិលតាមខេត្តចំនួន ១៥ ខេត្ត ដែលគោលដៅសំខាន់បីគឺ ទីមួយចង់ពង្រឹងស្ថាប័នរបស់សមាជិកបណ្តាញសង្គមស៊ីវិលតាមខេត្តឲ្យមានភាពរឹងមាំ ទីពីរចង់ពង្រឹងសមត្ថភាព និងផ្តល់ឱកាសឲ្យសមាជិកបណ្តាញសង្គមស៊ីវិលដើម្បីកៀរគរមូលនិធិ និងទីបីគឺចង់ចងក្រង ឬប្រមូលមតិរួមមកផ្សារភ្ជាប់ជាមួយអង្គការបណ្តាញសង្គមស៊ីវិលតាមខេត្ត និងអង្គការសហគមន៍មូលដ្ឋាន។ ក្នុងខែកញ្ញា ឆ្នាំ២០១៨ នេះក្រុមការងារយើង៦នាក់នឹងត្រូវបានបញ្ជូនទៅអភិវឌ្ឍផ្នែកកៀរគរធនធាននៅឯក្រៅប្រទេស ដែលមានពីរជំនាញ គឺមាន៤នាក់រៀនអំពីការកៀរគរធនធានមូលនិធិ ក៏ដូចជាសម្ភារ: ហើយនិង ២នាក់សម្រាប់ការតស៊ូមតិ បញ្ចុះបញ្ចូលដើម្បីឲ្យគេផ្តល់ធនធានមកយើង។ អ្នកទាំង ៦ នាក់នឹងចូលមកជួយពង្រឹងគ្រូបង្គោល តាមអង្គការសហគមន៍មូលដ្ឋានអោយចេះកៀរគរមូលនិធិ និងធ្វើជំនួញក្នុងការពង្រីកសហគមន៍។ ក្នុងពេលអនាគតដ៏ខ្លីនេះ គ.ស.ក នឹងមានកម្មវិធីពង្រឹងសមត្ថភាពអង្គការសហគមន៍មូលដ្ឋាន តាមរយ:សៀវភៅគោលការណ៍ណែនាំស្តីពីការប្រតិបត្តិល្អរបស់អង្គការសហគមន៍មូលដ្ឋាន។ និងមានការរើសគ្រូបង្គោលពីអង្គការដែលធ្វើការគាំទ្រអង្គការសហគមន៍មូលដ្ឋាន និងថ្នាក់ដឹកនាំរបស់អង្គការសហគមន៍មូលដ្ឋានមួយចំនួនតូចដែរ ប្រសិនជាអាច។ អង្គការ គ.ស.ក ក៏មានការរៀនសូត្រតាមអ៊ីនធឺណេត និងមានការបង្ហាត់បង្ហាញ និងជាចុងក្រោយយើងនឹងធ្វើការជាមួយគ្នាដើម្បីរកថវិកា ដោយចងគ្នាជាបណ្តាញ និងរកទីផ្សារសម្រាប់ផលិតផល។ លោកបានថ្លែងអំណរគុណជាថ្មីម្តងទៀតដល់សិក្ខាកាមទាំងអស់ដែលបានចំណាយពេលវេលាមកចូលរួម និងយកចិត្តទុកដាក់ពិភាក្សាក្នុងថ្ងៃនេះ ដើម្បីមកចែករំលែកនូវបទពិសោធន៍ និងបញ្ហាប្រឈមផ្សេងៗ សំដៅធ្វើយ៉ាងណាឲ្យការអភិវឌ្ឍកាន់តែប្រសើរឡើង។ ជាចុងបញ្ចប់លោកក៏បានជូនពរទៅសិក្ខាកាមទាំងអស់ និងប្រកាសបើកកិច្ចប្រជុំនៅថ្ងៃនេះ។



www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152
F +855 (0)23 216 009

#9-11, Street 476,
ToulTompoung 1, Chamkamorn
P.O. Box 885, Phnom Penh,Cambodia

## ការពិភាក្សាជាក្រុមតូចៗ ការត្រួតពិនិត្យឡើងវិញ និងការឆ្លុះបញ្ចាំងរបស់អង្គការសហគមន៍មូលដ្ឋាន សម្របសម្រួលដោយកញ្ញា កៅ ពៅលក្ខិណា អ្នកឯកទេសផ្នែកអង្គការសហគមន៍មូលដ្ឋាន

### ១. តើបញ្ហាអ្វីខ្លះ ដែលអង្គការសហគមន៍មូលដ្ឋានជួបប្រទះក្នុងការអនុវត្តការងាររបស់លោកអ្នក?

បញ្ហាប្រឈម ដែលអង្គការសហគមន៍មូលដ្ឋានជួបប្រទះក្នុងការអនុវត្តការងារមានដូចខាងក្រោម៖



- មិនទាន់បានចុះបញ្ជីក្នុងក្រសួង
- មិនទាន់មានការចូលរួមត្រួតពិនិត្យ និងវាយតម្លៃពីសហគមន៍
- សមត្ថភាព និងចំណេះដឹងនៅមានកម្រិតក្នុងការសរសេរបាយការណ៍ សម្របសម្រួល តស៊ូមតិ និងផ្នែកច្បាប់
- ខ្វះទំនាក់ទំនងរវាងសហគមន៍និងសហគមន៍ និងរវាងសហគមន៍និងស្ថាប័នពាក់ព័ន្ធ
- ខ្វះការគាំទ្រពីអាជ្ញាធរមូលដ្ឋាន
- ការខ្វះខាតធនធាន (ថវិកា មនុស្ស និងសម្ភារៈ)
- ខ្វះការយល់ដឹងទៅលើច្បាប់ ដែលទើបបង្កើតថ្មី និងរឹតបន្តឹងដល់អង្គការសហគមន៍មូលដ្ឋាន
- ការចូលរួមរបស់សហគមន៍មានកម្រិត (ចំណាកស្រុក)
- ការរៀបចំសមាសភាព រចនាសម្ព័ន្ធអង្គការសហគម៌មូលដ្ឋាន មិនបានសមស្របតាមលក្ខន្តិកៈនៅឡើយ
- បំរែបំរួលធម្មជាតិ
- សមាជិកមិនសូវចូលរួមជាមួយសហគមន៍
- មិនទាន់មានបណ្ដាញពីសហមន៍ទៅសហគមន៍មួយដើម្បីសហការគ្នា
- ជួបបញ្ហាទីផ្សារលក់ផលិតផល (នាំអោយសហគមន៍បែកបាក់)
- យុទ្ធសាស្ត្រ និងការធានានិរន្តភាពរបស់អង្គការសហគមន៍មូលដ្ឋានមិនទាន់បានច្បាស់លាស់
- សមត្ថភាព និងការយល់ដឹងរបស់គណៈកម្មការនៅមានកម្រិត
- ការលាបពណ៌ពីអ្នកនយោបាយ
- សកម្មភាពដែលជាតំរូវការរបស់សហគមន៍ អជ្ញាធរមិនបានដាក់បញ្ចូលទៅក្នុងផែនការវិនិយោគឃុំ
- ខ្វះសមត្ថភាពក្នុងការកៀរគរធនធាន
- ពិបាកទប់ស្កាត់ចំពោះបទល្មើសផ្សេងៗ (នេសាទមកពីក្រៅសហគមន៍)



www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152
F +855 (0)23 216 009

#9-11, Street 476,
ToulTompoung 1, Chamkamorn
P.O. Box 885, Phnom Penh,Cambodia

Accountability គណនេយ្យភាព
អភិបាលកិច្ច និងការប្រតិបត្តិ ប្រកបដោយវិជ្ជាជីវៈ
GPP
25/08/2015 24/08/2018
Symbol of Trust និមិត្តសញ្ញានៃភាពទុកចិត្ត

២. តើលោក អ្នកចង់ឃើញអង្គការសហគមន៍មូលដ្ឋានរបស់លោកអ្នកទៅជាយ៉ាងណា ទៅថ្ងៃអនាគត (រយៈពេល បី ទៅ ប្រាំឆ្នាំខាងមុខ)? សូមគិតទៅលើផ្នែក អភិបាលកិច្ច បរិយាកាសអំណោយផល ការកសាងសមត្ថភាព និងនិរន្តរភាព។

៣. តើលោកអ្នកគួរធ្វើដូចម្តេចខ្លះដើម្បីសម្រេចបាននូវសេចក្តីប៉ងប្រាថ្នាខាងលើនេះ?

| | អភិបាលកិច្ច | បរិយាកាសអំណោយផល | ការកសាងសមត្ថភាព | និរន្តរភាព |
|---|---|---|---|---|
| **ចង់ឃើញនៅបី ទៅប្រាំឆ្នាំក្រោយ** | - សមាជិកអង្គការមូលដ្ឋានមានការកើនឡើង<br>- ការដឹកនាំគ្រប់គ្រងសហគមន៍មូលដ្ឋានមានភាពរឹងមាំ (មានភាពជាម្ចាស់) | - កិច្ចសហការរវាងអង្គការមូលដ្ឋាន អាជ្ញាធរមានភាពរលូន<br>- ចង់អោយមានការគាំទ្រថវិកាពីរដ្ឋាភិបាល និងអង្គការដៃគូរ ជាពិសេសអាចរកចំណូលដោយខ្លួនឯង | - មានសមត្ថភាពស្វែងរកការគាំទ្រមូលនិធិសម្រាប់អង្គការសហគមន៍ដោយខ្លួនឯង<br>-ការដឹកនាំ គ្រប់គ្រងមានភាពទូលំទូលាយ<br>- សមាជិកមានជំនាញចំណេះដឹងច្បាស់លាស់ | -កិច្ចសហការពីរដ្ឋាភិបាល<br>-បង្កើតមុខរបរ<br>-ដំណើរការសហគមន៍អោយកាន់តែល្អ |
| **តើគួរធ្វើអ្វីខ្លះ?** | - ពង្រឹងរចនាសម្ព័ន្ធ បទបញ្ជាផ្ទៃក្នុង<br><br>- ការចងក្រង និងការគ្រប់គ្រងឯកសារសហគមន៍<br>- ការអនុវត្តលក្ខន្តិកៈនិតិរដ្ឋ | - ជំរុញអោយអង្គការសហគមន៍មូលដ្ឋានមានការចុះបញ្ជី<br><br>- កិច្ចសហការល្អជាមួយអាជ្ញាធរ និងអង្គការពាក់ព័ន្ធ<br>- ផ្សព្វផ្សាយពីគោលការណ៍ ទស្សនវិស័យបេសកកម្ម(VMG) របស់អង្គការសហគមន៍មូលដ្ឋាន<br>- ផ្សព្វផ្សាយច្បាប់ស្តីពីអង្គការមិនមែររដ្ឋាភិបាល និង សមាគម បានទូលំទូលាយ<br>- ជំរុញអោយមានការគាំទ្រ និងស្វែងរកថវិកាដើម្បីដំណើរការសហគមន៍ | - បណ្តុះបណ្តាលជំនាញ (ស្នើសុំគម្រោងក្នុងការគ្រប់គ្រង ការសរសេររបាយការណ៍ TOT នឹងឧបករណ៍មិនបង្កទំនាស់ផ្ទៃក្នុង(Do no Harm))<br>- ផ្តល់វគ្គបណ្តុះបណ្តាលដល់គណៈកម្មការ និងសមាជិកលើចំណេះដឹង ផ្សេងៗ<br>- ជំរុញ និងពង្រឹងការអនុវត្តផែនការ និងសកម្មភាពអោយបានល្អ<br>-ទស្សនៈកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍ | -បង្កើតក្រុមសន្សំ បង្កើតមុខរបរ និងទាញចំណូលពីអេកូទេសចរណ៍ និងសេវាកម្មផ្សេងៗ<br>-ការបង់វិភាគទាញពីសមាជិក |



www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152
F +855 (0)23 216 009

#9-11, Street 476,
ToulTompoung 1, Chamkamorn
P.O. Box 885, Phnom Penh,Cambodia

**៤. តើផ្នែកណាខ្លះនៃគោលការណ៍ណែនាំស្តីពីការប្រតិបត្តិល្អរបស់អង្គការសហគមន៍មូលដ្ឋានដែលលោកអ្នកបានយកទៅអនុវត្ត? ហើយបានជួយអ្វីខ្លះដល់អង្គការសហគមន៍មូលដ្ឋានរបស់លោកអ្នក? (សូមរៀបរាប់) តើមានបញ្ហាប្រឈមអ្វីខ្លះ?**

| ផ្នែកណាខ្លះបានយកទៅអនុវត្ត? | បានជួយអ្វីខ្លះ? | មានបញ្ហាប្រឈមអ្វីខ្លះ? |
|---|---|---|
| គោលការណ៍ណែនាំស្តីពីការប្រតិបត្តិល្អរបស់អង្គការសហគមន៍មូលដ្ឋានទាំងប្រាំបីចំនុច<br><br>-លក្ខណៈផ្លូវច្បាប់ និងការអភិវឌ្ឍអង្គការសហគមន៍មូលដ្ឋាន<br><br>-ការទំនាក់ទំនង កិច្ចសហការ និងការចងបណ្តាញ<br><br>-សមាជិកភាព និងការគ្រប់គ្រងសមាជិក<br><br>ការគ្រប់គ្រងហិរញ្ញវត្ថុ<br><br>- គណនេយ្យភាព និងតម្លាភាព<br>- ការចូលរួមអនុវត្ត ត្រួតពិនិត្យ និងវាយតម្លៃ<br>- យុទ្ធសាស្រ្ត និងការធានានិរន្តរភាព | ➢ ការទទួលស្គាល់ផ្លូវច្បាប់(ការចុះបញ្ជី) នៃសហគមន៍ជាមួយអាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់<br>➢ ពង្រឹងការចងក្រងសហគមន៍មូលដ្ឋានផ្សេងៗអោយប្រមូលផ្តុំជាបណ្តាញស្រុក ខេត្ត<br>➢ ការពង្រឹងលើការអនុវត្តតួនាទី និងភារកិច្ចសមាសភាពគណៈកម្មការដឹកនាំសហគមន៍<br>➢ អង្គការសហគមន៍មូលដ្ឋានមានភាពកិច្ចសហការបានយ៉ាងល្អ ក្នុងការទំនាក់ទំនងជាមួយអាជ្ញាធរ និងអង្គការដៃគូ<br>➢ បទបញ្ជាផ្ទៃក្នុង លក្ខន្តិកៈ និងគោលការណ៍គ្រប់គ្រងសមាជិកបានប្រសើរ<br>➢ ជាគម្រូក្នុងការវាស់វែងសមត្ថភាព និងចំនុចខ្វះខាតក្នុងអង្គការសហគមន៍មូលដ្ឋាន<br>➢ ទទួលបានការជឿជាក់ពីម្ចាស់ជំនួយ<br>➢ ការគ្រប់គ្រងចំណូលចំណាយបានល្អក្នុងការចាយវាយ (ការកត់ត្រាមានបញ្ជីស្នាមច្បាស់លាស់មានតម្លាភាព និងគណនេយ្យភាព<br>➢ មានការសរសេរផែនការយុទ្ធសាស្រ្តច្បាស់ ដែលធានាដល់និរន្តភាពអង្គការសហគមន៍មូលដ្ឋាន | ❖ សមាជិកមិនសកម្ម<br>❖ ខ្វះខាតថវិកាក្នុងការអនុវត្តគម្រោង<br>❖ សមត្ថភាព និងចំណេះដឹងសមាជិកនូវមានកម្រិត<br>❖ ពិបាកក្នុងការទំនាក់ទំនងជាមួយស្ថាប័ន ឬអាជ្ញាធរពាក់ព័ន្ធមួយចំនួន<br>❖ មិនសូវមានការចូលរួមពីគណៈកម្មការ<br>❖ សមត្ថភាព និងចំណេះដឹងគណៈកម្មការនៅមានកម្រិតក្នុងការសរសេររបាយការណ៍ប្រចាំឆ្នាំ និងវាយតម្លៃក្នុងការអនុវត្តគម្រោង<br>❖ បញ្ហាកត្តាជីវភាពគ្រួសារ |

**៥. តើលោកអ្នកត្រូវការការគាំទ្រអ្វីខ្លះ ពីអង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា និងអង្គការដៃគូពាក់ព័ន្ធ?**

- ➢ សូមអង្គការជួយសម្របសម្រួលបង្កើតសហព័ន្ធ និងបច្ចេកទេសក្នុងការចងក្រងជាបណ្តាញ
- ➢ សុំជួយរកទីផ្សារ(ផលិតផលកសិកម្ម)
- ➢ ផ្តល់វគ្គបណ្តុះបណ្តាល និងជំនាញបច្ចេទេស ដូចជាផ្នែកទឹកស្អាត ព្រៃឈើ កសិកម្ម និងការកែច្នៃផលិតផល នេសាទ យេនឌ័រ គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ (គ.ក.ន.ក)

- សូមអោយមានទស្សនកិច្ចសិក្សាតាមបណ្តាខេត្តផ្សេង
- ជួយពង្រឹងផ្នែកច្បាប់គ្រប់គ្រង និងដោះស្រាយបញ្ហា
- ជំនាញធ្វើផែនការ
- ស្វែងរកមូលនិធិ
- ជួយបង្រៀនពីរបៀបសរសេរគម្រោងស្នើរសុំថវិកា ការកៀរគរធនធានពីខាងក្រៅ
- ជួយពង្រឹងទំនាក់ទំនងជាមួយរដ្ឋាភិបាលដើម្បីទទួលស្គាល់អង្គការសហគមន៍មូលដ្ឋាន
- ជួយចុះវាយតម្លៃអង្គការសហគមន៍មូលដ្ឋាន និងសម្រេចក្នុងការផ្តល់វិញ្ញាបនប័ត្រ ក្នុងការអនុវត្តល្អទៅលើគោលការណ៍ទាំងប្រាំបី

## ការពិភាក្សាជាក្រុមតូចៗ ទៅលើច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ច្បាប់ស្តីពីសារពើពន្ធ និងច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពនៅកម្ពុជា សម្របសម្រួលដោយកញ្ញា កៅ ពៅលក្ខិណា អ្នកឯកទេសផ្នែកអង្គការសហគមន៍មូលដ្ឋាន

ការពិភាក្សាត្រូវបានចែកចេញជាពីរក្រុមធំៗ គឺមួយក្រុមជាអង្គការមិនមែនរដ្ឋាភិបាល ដែលពួកគាត់ធ្លាប់លឺ និងអនុវត្ត និងមួយក្រុមទៀតគឺក្រុមអង្គការសហគមន៍មូលដ្ឋាន ដែលពួកគាត់មិនធ្លាប់បានលឺ ឬបានលឺនិងដឹងតិចតួច តែមិនដែលអនុវត្តទេ។

I. ក្រុមអង្គការមិនមែនរដ្ឋាភិបាលដែលបានយល់ដឹង ឬបានអានឯកសារច្បាប់ស្តីពីសមាគម និងអង្គកាមិនមែនរដ្ឋាភិបាល ច្បាប់ស្តីពីសារពើពន្ធ និងច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម នឹងពិភាក្សាលើសំណួរដូចខាងក្រោម៖

**តើអង្គការសហគមន៍មូលដ្ឋានរបស់លោកអ្នកបានអនុវត្តហើយឬនៅ? ប្រសិនបើបានអនុវត្ត តើមានបញ្ហាប្រឈមអ្វីខ្លះ? តើមានសំណូមពរអ្វីខ្លះទៅដល់ក្រសួងពាក់ព័ន្ធ?**



a. **ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល**
ពួកគាត់បានអនុវត្តដូចតទៅ៖

- របនាសម្ព័ន្ធ ការដឹកនាំ លក្ខន្តិក: ការិយាល័យ ត្រូវតែជូនដំណឹងទៅក្រសួងមហាផ្ទៃ មុន១៥ថ្ងៃ
- ត្រូវផ្តល់របាយការណ៍ក្នុងខែ២ នៃឆ្នាំបន្ទាប់
- ផ្តល់លេខគណនីយដល់ក្រសួងមហាផ្ទៃ

b. **ច្បាប់ស្តីពីសារពើពន្ធ**
ពួកគាត់មានសំណួរ ក៏ដូចជាសំណូមពរដូចខាងក្រោម៖

- ចង់អោយក្រសួងពន្ធដារគួររៀបចំឯកសារបង់ពន្ធពី របៀបកាត់ពន្ធតាមប្រភេទនីមួយៗ? (បានបង់ពន្ធប្រាក់ខែ បណ្ណប៉ាតង់ ជួលអាគារ )
- តើបុគ្គលិកអង្គការសង្គមស៊ីវិលបានទទួលអត្ថប្រយោជន៍ពីការបង់ពន្ធនេះយ៉ាងណា?
- តើរដ្ឋបានពិចារណា ឬអនុគ្រោះពន្ធអ្វីខ្លះ?
- តើនីតិវិធីធ្វើសវនកម្ម យ៉ាងដូចម្តេច? (ប្រចាំឆ្នាំ ឬចំពោះ NGO ណាមួយមានបញ្ហា)?



c. **ច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម**

ពួកគាត់បានអនុវត្តដូចតទៅ៖

- ត្រូវផ្តល់របាយការណ៍ហិរញ្ញវត្ថុក្នុងខែ២ នៃឆ្នាំបន្ទាប់
- ផ្តល់លេខគណនីយដល់ក្រសួងហិរញ្ញវត្ថុ

**យើងមានយល់ដឹងពីគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពនៅកម្ពុជា**

ក. គោលដៅនេះអាចពាក់ព័ន្ធនឹងការងាររបស់ពួកគាត់ ដូចជា ស្បៀង សុខភាព ការអប់រំ ទឹកស្អាត បរិស្ថាន ជីវចំរុះ និងបម្រែបម្រួលអាកាសធាតុ

ខ. សូមឲ្យក្រសួង និងស្ថាប័នដែលពាក់ព័ន្ធចូលរួមសហការគ្នា។

II. ក្រុមអង្គការសហគមន៍មូលដ្ឋាន ដែលពួកគាត់មិនធ្លាប់បានលឺ ឬបានលឺនិងដឹងតិចតួច តែមិនដែលអនុវត្តទេ ពួកគាត់នឹងធ្វើការពិភាក្សាគ្នាថាតើពួកគាត់ចង់ដឹងអ្វីខ្លះអំពីច្បាប់ទាំងបី

a. **ច្បាប់ស្តីពីសមាគម និងអង្គកាមិនមែនរដ្ឋាភិបាល**

- ច្បាប់នេះមានប៉ុន្មានមាត្រា?
- តើច្បាប់នេះមានអត្ថប្រយោជន៍អ្វីខ្លះ?
- តើច្បាប់នេះគ្រប់ដណ្តប់ដល់នរណាខ្លះ? អាចទៅរកបាននៅកន្លែងណាខ្លះ?
- ច្បាប់នេះមានសុពលភាពលើសហគមន៍នេសាទដូចម្តេច?
- ច្បាប់នេះ តើវាមានផលប៉ះពាល់ដល់អង្គការ និងសហគមន៍ដែរឬទេ?
- ច្បាប់នេះបង្កើតឡើងនៅថ្ងៃខែឆ្នាំណា?
- តើមាត្រាទីប៉ុន្មានដែលសហគមន៍ត្រូវអនុវត្តន៍តាម?
- ការចងក្រងសន្សំប្រាក់នៅតាមសហគមន៍ តើច្បាប់នេះគ្របដណ្តប់ឬទេ?
- តើអ្នកប្រព្រឹត្តខុសពីច្បាប់នេះមានទោសរបៀបណា?

b. **ច្បាប់ស្តីពីសារពើពន្ធ**

- តើច្បាប់នេះទទួលផលប្រយោជន៍អ្វីខ្លះដល់សហគមន៍ / សមាគម?


www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152
F +855 (0)23 216 009

#9-11, Street 476,
ToulTompoung 1, Chamkamorn
P.O. Box 885, Phnom Penh,Cambodia
Accountability គណនេយ្យភាព
GPP
25/08/2015 24/08/2018
Symbol of Trust និមិត្តសញ្ញានៃភាពទុកចិត្ត

- ហេតុអ្វីសហគមន៍ / សមាគមត្រូវបង់ពន្ធ?
- តើធនធានរបស់សហគមន៍កម្រិតណាដែលត្រូវបង់ពន្ធ?
- តើច្បាប់នេះត្រូវលើកលែងសម្រាប់សមាគមន៍ដែរឬទេ?
- តើរដ្ឋមានការអនុគ្រោះពន្ធលើអ្វីខ្លះ?
- តើច្បាប់នេះអាចទៅរកបាននៅកន្លែងណាខ្លះ?
- តើច្បាប់នេះបានផ្សព្វផ្សាយដល់កម្រិតណា?

c. **ច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម**

- តើច្បាប់នេះមានន័យដូចម្តេច? ហើយនិយាយពីអ្វីខ្លះ?
- តើច្បាប់នេះប្រើប្រាស់ដើម្បីប្រយោជន៍អ្វីខ្លះ?
- តើច្បាប់នេះមានតួនាទីអ្វីខ្លះ?
- តើច្បាប់នេះមានការគ្របដណ្តប់កម្រិតណា?
- ក្នុងករណីសមាគមន៍ធ្វើសកម្មភាព តើចាំបាច់ផ្តល់របាយការណ៍ហិរញ្ញវត្ថុដែរឬទេ?

**មិនទាន់ដឹងពីគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពនៅកម្ពុជាទេ។ តែគ្រាន់តែចង់សួរថា**

តើគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពមានអ្វីខ្លះ?

សុន្ទរកថាបិទ ដោយ លោក ស៊ឹង ទីប៉ូ អ្នកគ្រប់គ្រង ផ្នែកអភិវឌ្ឍន៍សមត្ថភាព ដែលជាតំណាងមកពីអង្គការ គ.ស.ក

លោកបានថ្លែងអំណរគុណ និងលើកសរសើរដល់អង្គសិក្ខាកាមដែលបានចូលរួម និងពិភាក្សាយ៉ាងផុសផុលក្នុងកិច្ចប្រជុំនេះដើម្បីយកជាគំនិតរួមក្នុងការអភិវឌ្ឍសហគមន៍ ហើយក៏លើកជាបញ្ហាដើម្បីរកគន្លឹះកសាងសមត្ថភាព និងចំណេះដឹងរបស់តំណាងអង្គការសហគមន៍មូលដ្ឋានអោយមានភាពប្រសើរនៅពេលអនាគត (ប្រធានបទទី១)។ មួយវិញទៀតការពិភាក្សាលើប្រធានបទទី២ គឺសម្រាប់ជាឱកាសដល់សិក្ខាកាមសិក្សាស្វែងយល់ និងរៀបចំត្រៀមជាសំណួរដែលត្រូវរកចម្លើយពីវាគ្មិនមកពីក្រសួងពាក់ព័ន្ធ នៅថ្ងៃស្អែកក្នុងកម្មវិធីកិច្ចពិគ្រោះយោបល់ថ្នាក់ជាតិស្តីពីការអភិវឌ្ឍន៍គោលនយោបាយ និងក្របខណ្ឌច្បាប់ពាក់ព័ន្ធនឹងអង្គការសង្គមស៊ីវិល។ លោកក៏បានជូនពរដល់សិក្ខាកាមទាំងអស់មានសុខភាពល្អ និង សំណាងល្អ។

==============================


www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152
F +855 (0)23 216 009

#9-11, Street 476,
ToulTompoung 1, Chamkamorn
P.O. Box 885, Phnom Penh,Cambodia
Accountability គណនេយ្យភាព
GPP
25/08/2015 24/08/2018
Symbol of Trust